ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា

លេខ : ៥៧៥០ សជណ-អក-ទប

# សេចក្តីជូនដំណឹង

## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិក ចំនួន ២១រូប ដើម្បីចូលបម្រើការងារ នៅអគ្គិសនីខេត្តព្រះសីហនុ នៃអគ្គិសនីកម្ពុជា ដូចខាងក្រោម :

*- **លក្ខណៈសម្បត្តិបេក្ខជន** :

១- បុគ្គលិកផ្នែកបណ្តាញ-ចែកចាយ ចំនួន ០៣ រូប :

- បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%
- កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រវិស្វករអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ជាមធ្យម ។

២- ភ្នាក់ងារជំឡើងជួសជុលនិងថែទាំបណ្តាញ MV និង បុគ្គលិកបើកបរម៉ាស៊ីននិងទូបញ្ជា សរុបចំនួន ១៧ រូប :

- បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%
- កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ជាមធ្យម ។

៣-ភ្នាក់ងារត្រួតពិនិត្យ ចំនួន ០១ រូប :

- បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.I.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%
- កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រវិស្វករអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ជាមធ្យម ។

*- **បញ្ជាក់** : បេក្ខនារីគ្រប់ខេត្ត-ក្រុង និងបេក្ខជន ដែលមានអាសយដ្ឋានស្ថិតនៅខេត្តសាមី ប្រសិនបើលទ្ធផលពិន្ទុប្រហាក់ប្រហែលគ្នា គឺត្រូវផ្តល់អាទិភាព។

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

| | |
|---|---|
| - ពាក្យសុំចូលបម្រើការងារ | ចំនួន ០១ ច្បាប់ |
| - ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ | ចំនួន ០១ ច្បាប់ |
| - ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ មានបញ្ជាក់ពីអាជ្ញាធរដែនដី | ចំនួន ០១ ច្បាប់ |
| - តារាងពិន្ទុ (TRANSCRIPT) | ចំនួន ០១ ច្បាប់ |

*- ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធ I នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រលងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម ។

*- **ទីកន្លែងទទួលពាក្យ** : សាលប្រជុំអគារ C ជាន់ទី៣ នៃអគ្គិសនីកម្ពុជា

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ  រហូតដល់ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៥ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០
- ពាក្យសុំចូលបម្រើការងារ ត្រូវប្រើប្រាស់គំរូ មានបោះត្រាសម្គាល់របស់អគ្គិសនីកម្ពុជា។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៥

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**អគ្គនាយករង**

ELECTRICITE DU CAMBODGE

**អេង_គន្ធា**

**បញ្ជាក់**

- សេចក្តីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់ អគ្គិសនីកម្ពុជា គឺ :www.EDC.com.kh។